BMI0101

# សម្ភាសន៍ជាមួយឈ្មោះ អន សំអ៊ុន ភេទប្រុស អាយុ៨៧ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម“កងចល័ត”

## រស់ភូមិយានវៀន ឃុំផ្តៅ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

០០ៈ៣៤ៈ២៩

២៣ទំព័រ

ប៊ុនថនៈ ជាដំបូងចង់សួរឈ្មោះ ពូ ពូឈ្មោះអីដែរ?

សំអ៊ុនៈ បាទ!ខ្ញុំឈ្មោះអន សំអ៊ុន។

ប៊ុនថនៈ ពូអាយុប៉ុន្មានហើយពូ?

សំអ៊ុនៈ អាយុ៨៧ឆ្នាំហើយ។

ប៊ុនថនៈ ស្រុកកំណើតនៅណាដែរ?

សំអ៊ុនៈ ស្រុកកំណើតនៅនេះនៅភូមិដើងវៀន ឃុំផ្តៅ ស្រុកស្វាយចេកហ្នឹងឯង។

ប៊ុនថនៈ ហើយពូរៀនសូត្រដល់ណាដែរ?

សំអ៊ុនៈ កាលរៀនសូត្រពីដើមមិញប្តូបច្ចុប្បន្ន។

ប៊ុនថនៈ បាទ។

សំអ៊ុនៈ ពីដើមមិញលោកគ្រូខ្ញុំរៀនបានថ្នាក់ទីទាបបំផុតតែដល់ការចេះដឹងក្រោយខ្ញុំរៀនបានដល់ថ្នាក់ទី៩ថ្នាក់ទី១១សង្គមមិញ។

ប៊ុនថនៈ បាទ!ថ្នាក់ទី១១?

សំអ៊ុនៈ បាទ។

ប៊ុនថនៈ គេរាប់ពីលើចុះក្រោម?

សំអ៊ុនៈ បាទ!ពីលើចុះក្រោម។

ប៊ុនថនៈ ពូរៀននៅសាលាណាដែរ?

សំអ៊ុនៈ រៀននៅសាលាពាក់កណ្តាលភូមិផ្តៅ កាលហ្នឹងមានភូមិម៉ោងនិងដើងវៀនហ្នឹងពាក់កណ្តាលគ្នា។

ប៊ុនថនៈ គេហៅសាលាអីដែរ?

សំអ៊ុនៈ សាលាបឋមសិក្សាវាមានថ្នាក់ទាបថ្នាក់ខ្ពស់ដែលកាលហ្នឹង ។

ប៊ុនថនៈ ចឹងពូឈប់រៀននៅឆ្នាំណា?

សំអ៊ុនៈ ឈប់រៀននៅឆ្នាំ៧៣ ខ្មែរក្រហមចាប់ផ្ដើមវ៉ៃលុកចូលទីក្រុងភ្នំពេញខ្ញុំចាប់ផ្ដើមឈប់ពេលនោះឯងព្រោះគ្រូគាត់ចេញអស់រលីងពីស្រុកពីស្រែហ្នឹង ។

ប៊ុនថនៈ ហ្នឹង៧៥?

សំអ៊ុនៈ អត់ទេ ៧៤លោកគ្រូ ។

ប៊ុនថនៈ ៧៤?

សំអ៊ុនៈ បាទ ។

ប៊ុនថនៈ ចឹង៧៤ពូឈប់រៀន?

សំអ៊ុនៈ បាទ!ឈប់រៀនព្រោះមានសង្គ្រាមកើតឡើង ។

ប៊ុនថនៈ បាទ!ម៉េចបានឈប់?

សំអ៊ុនៈ កាលហ្នឹងខ្មែរក្រហមវាចូលមកបំបែកបំបាក់ហើយ សូម្បីតែលោកសង្ឃគេផ្សឹកហើយយន្តហោះទម្លាក់នៅភូមិផ្ទាំយើងនេះ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ដឹងស្រាប់ហើយសង្គ្រាម ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ហើយកូនសិស្សបែកបាក់ហើយលោកគ្រូបែកបាក់មុនកូនសិស្សទៀត ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ យើងឈប់រៀនត្រឹមហ្នឹងមកលោកគ្រូ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ យើងបញ្ចប់ត្រឹមហ្នឹងតែម្ដង ។

ប៊ុនថនៈ ចឹងសាលាផ្សេងៗក្នុងភូមិ?

សំអ៊ុនៈ អត់មានទេលោកគ្រូ អត់មានទេគឺឈប់ទាំងអស់ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ភូមិផងរបងជាមួយជុំវិញខេត្តបន្ទាយមានជ័យ កាលពីមុនគេហៅខេត្តបាត់ដំបង ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ចាប់ពីបាត់ដំបងមកខាងជើងមានតែផ្សែងគ្រាប់បែកមានតែយន្តហោះទម្លាក់ ព្រោះខ្មែរក្រហមចូលមកវាធ្វើសង្គ្រាមកាលហ្នឹង ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ដូចដឹងហើយកាលនោះ ។

ប៊ុនថនៈ យន្តហោះរបស់ខាងណាវិញពូ?

សំអ៊ុនៈ យន្តហោះរបស់អាមេរិចកាំងមកពីភ្នំពេញមកកាលហ្នឹងទម្លាក់ខ្មែរក្រហម ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ទម្លាក់បំផ្លាញខ្មែរក្រហមទម្លាក់បំបែកបំបាក់កងទ័ពរបស់វា តែវាអត់ទៅណាកងទ័ពខ្មែរក្រហមវានៅតែធ្វើសង្គ្រាមរហូតដល់ចប់ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ដល់វាសម្រេចគោលការណ៍របស់វា ។

ប៊ុនថនៈ តែនៅនេះមានខ្មែរក្រហមចូលភូមិទេពូ?

សំអ៊ុនៈ មាន ចាំមើលណាស់លោកគ្រូ សង្គ្រាមពីបចាប់ផ្តើមពីបម៉ោង៥ គេអូរទាហានហៅមកវិញមកដល់ទម្លាក់គ្រាប់បែកដឹង១ស្អែកឡើងឈប់ទម្លាក់ខ្មែរក្រហមចូលដល់ភូមិពេញ ។

ប៊ុនថនៈ បាទ!ចឹងទម្លាក់អត់ដែលត្រូវខ្មែរក្រហម?

សំអ៊ុនៈ អត់មានប៉ះពាល់ទេ មានតែប៉ះពាល់ផ្ទះបងប្អូនសាលារៀនបងប្អូនគឺឆេះអស់ ។

ប៊ុនថនៈ ចឹងត្រូវតែជនស៊ីវិលទេ?

សំអ៊ុនៈ បាទ!ត្រូវតែជនស៊ីវិលកាលពីដើមមិញមិនមែនទម្លាក់គ្រាប់ធម្មតាទេ លោកគ្រូទម្លាក់សុទ្ធតែ“អាបេ៥២” ។

ប៊ុនថនៈ អ! ។

សំអ៊ុនៈ ទម្លាក់អាបេ៥២គ្រាប់ប៉ុណ្ណាប៉ុនណឹឆេះអស់ហើយពីក្អាសដល់ផ្កាំរហូតដល់ថ្មពួកឆេះខ្ទិច ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ហើយការសិក្សាអត់មានចូលប៉ុន្មានទេ កាលហ្នឹងខ្ញុំរៀនបានត្រឹម“អា បេ សេ”ប៉ុណ្ណឹងទេចប់ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ មិនមែនដូចសព្វថ្ងៃយើងទេ “អេ ប៊ី ស៊ី ឌី”ក្មេងវាចេះអង់គ្លេសខ្លះ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ កាលនោះមានបានរៀនណាសន្ត្រាមបែកបាក់គ្នាបណ្ដោយ ។

ប៊ុនថនៈ ចឹងភូមិមៅអីមានប៉ះពាល់ទេ?

សំអ៊ុនៈ អត់មានប៉ះពាល់ទេ ប៉ះពាល់តែទួលឃុំផ្កាំបណ្ដោយ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ទម្លាក់គ្រាប់បែក៥២ឆេះខ្ទិចខ្ទីអស់ បើសិនជាពួកស៊ីម៉ាកគេរកអាចមាននៅមិនមាននៅ ខ្ញុំមិនដឹងទេរឿងហ្នឹង តែវាខ្ទិចខ្ទីអស់ហើយ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ចុះប្រជាពលរដ្ឋវានិរាស្ដចេញអស់រលីងហើយ ។

ប៊ុនថនៈ ចឹងកាលហ្នឹងពូមានផ្ទះនៅនេះតើ?

សំអ៊ុនៈ បាទ!ខ្ញុំស្រុកកំណើតនៅនេះឯង ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ នៅហ្នឹងជួបជុំឪពុកម្ដាយខ្ញុំនៅហ្នឹង ហើយដល់ចប់ឆ្នាំ៧៥មក ៧៥បន្តបន្ទាប់មកគេរំដោះបានហើយគេចង់ខ្មែរក្រហមគគ្រប់ដែនបានហើយគេចាប់ផ្ដើមសម្លាប់មនុស្ស ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ដល់គេចាប់ផ្ដើមសម្លាប់មនុស្សគេយកឪពុកម្ដាយខ្ញុំទៅសម្លាប់អស់រលីងនៅសល់ខ្ញុំកំព្រាគត់សព្វថ្ងៃហ្នឹង ។

ប៊ុនថនៈ យ៉ាងម៉េចបានជាគេយកទៅ?

សំអ៊ុនៈ គេដឹងប្រវត្តិឪពុកខ្ញុំធ្វើទាហាន ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ បាទ!ធ្វើទាហានហើយគេយកប្រវត្តិទាហានទៅសម្លាប់ចោល ។

ប៊ុនថនៈ គាត់ធ្វើទាហានខាងណា?

សំអ៊ុនៈ ទាហានលន់ នល់យើងហ្នឹងទាហានពីដើមមិញពីសង្គមហ្នឹង ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ យកទៅសម្លាប់ចោលអស់គ្មានសល់ទេមួយភូមិៗនោះ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ បានថាអំណាចឈឺចាប់របស់ខ្មែរក្រហមហ្នឹងនិយាយទៅវាវែងឆ្ងាយណាស់ ។

ប៊ុនថនៈ ចឹងម្ដាយលោកពូ?

សំអ៊ុនៈ ទាំងអស់គ្មានសល់ទេ គេថាដកស្មៅមួយគុម្ពត្រូវដកទាំងឫសបានបាត់ការឈឺចាប់ ដូច្នេះនៅសល់តែខ្ញុំ ខ្ញុំនៅចល័តដែលខ្ញុំទៅឆ្ងាយជាងគេទៅមុខមកវិញឳពុកម្តាយស្លាប់អស់រលីងនៅសល់តែផ្ទះមើលលែងស្គាល់កោះក្រោយភ្នែកខួរក្បាលរបស់ខ្ញុំវាឆ្កែតអស់រលីងគ្មាននិយាយរួចទេ ។

ប៊ុនថនៈ បាទ!គេយកទៅសម្លាប់នៅឆ្នាំណាលោកពូ?

សំអ៊ុនៈ គេយកទៅសម្លាប់នៅឆ្នាំ៧៨លោកគ្រូ ។

ប៊ុនថនៈ ឆ្នាំ៧៨?

សំអ៊ុនៈ ៧៧-៧៨ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ វាចាប់ផ្តើមសម្លាប់ប្រជារាស្ត្រទាំងអស់ខ្មែរក្រហម ឳពុកខ្ញុំសួរប្រពន្ធខ្ញុំគ្មានសល់ទេ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ព្រោះប្រវត្តិឳពុកខ្ញុំធ្វើទាហាន ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ហើយបច្ចុប្បន្ននេះខ្ញុំក៏ធ្វើជាទាហានដូចគ្នាដែរ ខ្ញុំនឹកឃើញថានៅមិនដឹងជានៅធ្វើអីនៅតែលគោលខ្ញុំក៏ធ្វើជាចលនាជាមួយលោកតា សឺន សានកាលនោះណាស់ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ហ្នឹងឯង ។

ប៊ុនថនៈ ចឹងបងប្អូនលោកពូ?

សំអ៊ុនៈ មិនមានទេ ។

ប៊ុនថនៈ បងប្អូនប៉ុន្មាននាក់លោកពូ?

សំអ៊ុនៈ មួយពូជមាន៧នាក់យកទៅទាំងអស់ ។

ប៊ុនថនៈ ចឹងទាំងពីរ៨?

សំអ៊ុនៈ ៧ទៅទាំងអស់រាប់ទាំងម៉ែឳ៩នាក់ ។

ប៊ុនថនៈ ៩នាក់?

សំអ៊ុនៈ បាទ!រាប់តែប្អូនខ្ញុំគឺ៧នាក់ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ សម្លាប់បុសលានកាលនោះ ។

ប៊ុនថន: ចឹងពូអាចរៀបរាប់ពេលចូលមកដល់ដំបូង?

សំអ៊ុន: ខ្ញុំរៀបរាប់បានកាលចូលដំបូងនៅស្រុកខ្មែរលោកពូ ។

ប៊ុនថន: ចូលមកដំបូងនៅភូមិ?

សំអ៊ុន: ចូលមកដំបូងនៅភូមិនេះ ។

ប៊ុនថន: បាទ ។

សំអ៊ុន: ភូមិខ្ញុំភូមិកំណើត ។

ប៊ុនថន: បាទ ។

សំអ៊ុន: ខ្ញុំជំរាបលោកគ្រូឯងចូលមកដល់ដំបូង ខ្ញុំតែលគោលទាំងអស់គ្មានភូមិគឺភូមិចារាំងទាំងអស់ ភូមិគឺគ្មានមនុស្សនៅទេ ។

ប៊ុនថន: បាទ ។

សំអ៊ុន: ខ្ញុំក៏សង្ឃឹមទៅលើម៉ែឪតែដល់ខ្ញុំមកតែខ្លួនខ្ញុំទទេសុទ្ធ ។

ប៊ុនថន: បាទ ។

សំអ៊ុន: ខ្ញុំមកអាណោចអធម្មជាងគ្រោះសព្វថ្ងៃដែលស៊ីស្ពានកោះពេជទៅទៀត ជាងខ្យល់ព្យុះនៅប្រទេសឥណ្ឌាទៅទៀត តែខ្ញុំមិនដឹងជាធ្វើយ៉ាងម៉េចវាទូទៅៗហើយ ។

ប៊ុនថន: បាទ ។

សំអ៊ុន: សង្គ្រាមវាកើតឡើងមកវាតែងតែខូចខាតប្រជាពលរដ្ឋ ។

ប៊ុនថន: បាទ ។

សំអ៊ុន: ខ្ញុំខឹងនិងគេមិនដឹងជាធ្វើយ៉ាងម៉េច ព្រោះថាខឹងនិងគេយកទោសហ្នឹងគេច្បាំងនិងគេក៏វាគ្មានន័យអីពីព្រោះឪពុកម្តាយគេស្លាប់ដូចគ្នា ។

ប៊ុនថន: បាទ ។

សំអ៊ុន: ចឹងបានជាខ្ញុំសុខចិត្តតស៊ូ ជីវិតដើម្បីតស៊ូវាត្រូវតែតស៊ូរស់ ។

ប៊ុនថន: ចឹងកាលខ្មែរក្រហមចូលដល់ដំបូងខ្មែរក្រហមនៅភូមិឃុំហ្នឹង?

សំអ៊ុន: នៅទាំងអស់លោកគ្រូគេបែកចែកកម្មវិធី គេជ្រើសរើសឲ្យជឿអង្គការគេ គោរពអង្គការហ្នឹង ។

ប៊ុនថន: បាទ ។

សំអ៊ុន: អ្នកធ្វើទាហានអ្នកមានប្រវត្តិធ្វើទាហានអ្នកកម្មករសុទ្ធគេឲ្យទៅស៊ីបាយរឹងបាយជ្រាយណាស្រេចតែគេបែកចែកណាស់ ។

ប៊ុនថន: បាទ ។

សំអ៊ុន: តែការពិតគេកុហក់បោកប្រាស់យើងទេ ។

ប៊ុនថន: បាទ ។

សំអ៊ុន: គេយកទៅសម្លាប់ចោលឲ្យតែអ្នកដែលស្លូតត្រង់ដែលមិនមានវត្តមានជាមួយគេ គេបញ្ជូនឲ្យទៅធ្វើកម្មករលើសែនស្អី១ ស្រេចតែគេ ។

ប៊ុនថន: បាទ ។

សំអ៊ុន: ឪពុកខ្ញុំដែលជាប្រវត្តិទាហាន អ្នកណានៅក្នុងចង្កោមឲ្យតែមានប្រវត្តិជាទាហានចាស់គេមានការងាររមួយឲ្យធ្វើទៀត ។

ប៊ុនថន: បាទ ។

សំអ៊ុន: ពីសង្គមគេចាប់ផ្តើមចុះឈ្មោះ ដកចេញ គេកុហក់យើងថាគេយកយើងទៅរៀនសូត្រឲ្យយើងស៊ីបាយរីងឲ្យយើងឆ្ងាញ់ឲ្យយើងសុខស្រួលដេកស្រួលការពិតគេយកទៅសម្លាប់ចោល ។

ប៊ុនថន: បាទ!ចូលមកដល់ក្លាប់សម្លាប់ក្លាមឬក៏មិនទាន់ទេ?

សំអ៊ុន: អត់ទេ លោកគ្រូនិយាយទៅកាន់តែវែងឆ្ងាយ មិនមែនចូលដល់ក្លាមសម្លាប់ក្លាមទេ ។

ប៊ុនថន: បាទ ។

សំអ៊ុន: ចូលមកបានរយៈពីរខែបានគេចាប់ផ្តើមរៀបចំ រៀបចំហើយគេស្រាវជ្រាវអ្នកដែលមានប្រវត្តិពីដើម១មកអ្នកឯងធ្វើទាហានអ្នកឯងធ្វើការងារប៉ូលីសគយប៉េអ៊ឹមពីដើម១សង្គមមែនទេ ដល់ហើយគេចុះឈ្មោះ ។

ប៊ុនថន: បាទ ។

សំអ៊ុន: គេចុះឈ្មោះ គេចុះចោលដល់ពេលគេហៅយើង យើងមិនបានដឹងខ្លួន ។

ប៊ុនថន: បាទ ។

សំអ៊ុន: ស្រាប់តែគេបញ្ជូនយើងទៅ យើងស្លាប់បណ្តោយ កាលហ្នឹងបីរណ្តៅប្រហែលជា៣០០គ្រួសារ ។

ប៊ុនថន: នៅណាពូ?

សំអ៊ុន: នៅខាងត្បូងភូមិម៉ៅ ភូមិយើងនេះពាក់កណ្តាលម្នាក់ ។

ប៊ុនថន: ឥឡូវមាននៅឆ្អឹងអីទេ?

សំអ៊ុនៈ	ឆ្នឹងកាលពីមុនគេយកមកធ្វើបុណ្យរួមប្រហែលជានៅសល់ខ្លះដែរ«ប្រពន្ធគាត់និយាយថាកូនក្មេងគេចាប់ដើងបោក»។

ប៊ុនថនៈ	កន្លែងហ្នឹងជាងកន្លែងឃុំឃាំងឬជាកន្លែងសម្លាប់?

សំអ៊ុនៈ	អត់ទេ	កន្លែងគេជីករណ្ដៅទុកមិនឲ្យយើងដឹងខ្លួនទេ	ពួកយោធាវាហ៊ុំភូមិទាំងអស់យកឈ្មោះដូចខ្ញុំថាចឹង យកឈ្មោះអ្នកមានប្រវត្តិយកទៅដល់សម្លាប់ចោលហើយ ។

ប៊ុនថនៈ	បាទ!ចឹងពូចូលមកដំបូងចឹងប្រជាជននៅនេះដូចថាមានអ្នកថ្មីចូលមកទេ?

សំអ៊ុនៈ	អ្នកថ្មីកាលដែលខ្ញុំចូលមកដំបូងកាលបែកបាក់អ្នកថ្មីគេជម្លៀសទៅស្រុកគេវិញហើយអ្នកដែលរស់សល់ពីស្លាប់គេទៅស្រុករៀងៗខ្លួន តែខ្ញុំមកដល់ពីបផ្ទះភូមិទាំងអស់គឺរាំង ។

ប៊ុនថនៈ	បាទ ។

សំអ៊ុនៈ	រាំងសល់ខ្មែរក្រហមប៉ុន្មាននាក់បើនិយាយទៅ៧មករាហ្នឹងគេដេញចេញខ្មែរក្រហមអស់បានយើងបានសុខ ។

ប៊ុនថនៈ	ចឹងខ្ញុំចង់សួរសម័យ៧៥?

សំអ៊ុនៈ	សម័យ៧៥ខ្ញុំនៅហ្នឹងឯង ។

ប៊ុនថនៈ	នៅហ្នឹងតែម្ដង?

សំអ៊ុនៈ	បាទ ។

ប៊ុនថនៈ	អត់មានជម្លៀសពូទៅណាទៀតទេ?

សំអ៊ុនៈ	អត់ទេ ។

ប៊ុនថនៈ	ពូនៅធ្វើការក្នុងភូមិហ្នឹង?

សំអ៊ុនៈ	បាទ!និយាយពីប្រវត្តិកាលនោះ ។

ប៊ុនថនៈ	បាទ ។

សំអ៊ុនៈ	និយាយប្រវត្តិកាលនោះ៧៥-៧៨ចុះ ។

ប៊ុនថនៈ	បាទ ។

សំអ៊ុនៈ	៧៥ចាប់ផ្ដើមរៀបចំហើយណាស់ ។

ប៊ុនថនៈ	បាទ ។

សំអ៊ុនៈ	៧៥ខ្ញុំនៅហ្នឹងឯង	រៀបចំបំបែកខ្ញុំដែលលោកគ្រូតែបំបែកដោយអកុសលខ្ញុំប្រពន្ធខ្ញុំទៅឆ្ងាយដែរ ទៅអាង តា ម៉េង អាងត្រពាំងថ្មលយើងហ្នឹងសព្វថ្ងៃហ្នឹងលោកគ្រូ ។

ប៊ុនថនៈ	បាទ ។

សំអ៊ុនៈ ហ្នឹងឯងគេជម្លៀសចេញទៅទាំងអស់ តែខ្ញុំដាក់ឈ្មោះខាងមហាជនធ្វើស្រែសាបព្រោះ ខ្ញុំនៅភូមិគេនេះ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ តែភូមិកំណើតខ្ញុំគេមិនដឹងទេ ដូចខ្ញុំថាចឹងឯង ។

ប៊ុនថនៈ គេជម្លៀសគាត់ចេញទៅណា?

សំអ៊ុនៈ គាត់មិនជម្លៀសទេ គាត់នៅក្នុងស្រុកដល់គេចុះឈ្មោះត្រូវការយកទៅសម្លាប់ គេយកទៅសម្លាប់ទៅទាំងអស់បណ្តោយហើយខ្ញុំទៅជាចល័តនៅជាមហាជនខ្ញុំនៅសល់ ។

ប៊ុនថនៈ បាន ។

សំអ៊ុនៈ បើខ្ញុំបន្លាញថាខ្ញុំនៅតាមភូមិខ្ញុំស្លាប់អស់ហើយ ។

ប៊ុនថនៈ ទៅកងចល័ត?

សំអ៊ុនៈ មហាជនលោកគ្រូឯងដូចថាគេធ្វើការកម្មគេធ្វើការដូចជាស្មីសហករណ៍គេធ្វើការណាគេ ជំរុញខ្ញុំ ខ្ញុំដឹកបន្ទែរទេះគោក្របីទាំងអស់ ដូចជាយើងកេណ្ឌម៉ូតូឡានចឹងណាស់ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ដល់មកវិញឪពុកម្តាយស្លាប់ ។

ប៊ុនថនៈ កាលហ្នឹងដឹកទៅខាងណាខ្លះពូ យកទៅឲ្យសហករណ៍ណាខ្លះ?

សំអ៊ុនៈ ខ្ញុំយកទៅសហករណ៍ស្រេចតែគេបញ្ជា ត្រពាំងថ្ម ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ព្រោះចល័តគេទៅនោះឯង ចល័តគេទៅខាងនេះ ។

ប៊ុនថនៈ ដឹកយកទៅឲ្យគេពូ?

សំអ៊ុនៈ ដឹកបន្លែដឹកអង្ករដឹកស្បៀងចុះខ្ញុំចុះឈ្មោះជាមហាជននោះ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ បើខ្ញុំមិនចុះឈ្មោះជាមហាជនខ្ញុំជាកុមារខ្ញុំស្លាប់បាត់ហើយ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ព្រោះខ្ញុំកាន់ក្តាប់គោក្របីទាំងអស់ ប៉ុន្មានរយក្បាលលើខ្ញុំដល់ពេលគេត្រូវការគេតេមកខ្ញុំ បើយើងនិយាយថាតេនោះណាស់ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ គេឲ្យសំបុត្រមកថាត្រូវដឹកទៅសហករណ៍នេះសហករណ៍នោះ ដឹកបន្លែប៉ុន្មានមុខអង្ករស្បៀងប៉ុន្មានទៅយកពីសហករណ៍ខ្ញុំរៀបចំរទេះសំបែងរទេះបីបួនប្រាំគ្រឿង ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ជូនគេរួចត្រឡប់មកវិញ ឃ្វាលគោវិញធម្មតា ។

ប៊ុនថនៈ ចឹងបន្លែបានមកពីណាវិញ?

សំអ៊ុនៈ បន្លែមហាជនហ្នឹងឯងជាអ្នកដាំនោះ ខ្ញុំហ្នឹងហើយជាអ្នកដាំនោះ ។

ប៊ុនថនៈ ចឹងដាំហើយដឹកទៅ?

សំអ៊ុនៈ ដាំហើយដឹកឲ្យគេ យើងដាំហើយយើងបេះមួយទងមិនបានទេលោកគ្រូ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ យើងដាំហើយយើងត្រូវទទួលខុសត្រូវខ្លួនយើង យើងដាំហើយយើងបេះស៊ីយើងមានទោសទៀត ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ អត់បានទេ កាលហ្នឹង ។

ប៊ុនថនៈ មួយក្រុមមានប៉ុន្មាននាក់?

សំអ៊ុនៈ មួយក្រុមអីនិយាយមួយសហករណ៍ មួយសហករណ៍គឺមួយឃុំ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ លោកគ្រូឯងដាំអីបាន លោកគ្រូឯងហ៊ានតែបេះបានមិនបានទេ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ចូលរួមទាំងអស់ ។

ប៊ុនថនៈ ប្រមូលយកទាំងអស់?

សំអ៊ុនៈ ប្រមូលដាក់រួមទាំងអស់ ។

ប៊ុនថនៈ ចឹងដាក់រួមហើយបានពូបែងចែកឲ្យទៅតាមសហករណ៍?

សំអ៊ុនៈ គេហៅមកពីលើថ្នាក់លើគេហៅមក ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ សហករណ៍គេហៅមកថា ក្រុមគោខាងនេះត្រូវដឹកស្បៀងខាងនេះទៅឲ្យខាងពួកចល័ត ខ្ញុំដឹកទៅឲ្យគេខាងនេះប៉ុន្មានរទេះ៥រទេះ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ស្អែកឡើងខាងនោះខាងម៉ោខាងណាគេដឹកទៅឲ្យទៅព្រោះស្បៀងចេញចូលពេលថ្ងៃ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ហើយបន្ទៃបន្ទុកអីយើងអ្នកដាំហ្នឹងឯង អ្នកមហាជនជាអ្នកដាំ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ អ្នកដាំជាអ្នកដោះស្រាយឲ្យគេ បើនិយាយទៅមានកងជួរមុខកងជួរក្រោយ ។

ប៊ុនថនៈ កងជួរក្រោយ?

សំអ៊ុនៈ កងជួរក្រោយជាអ្នកបណ្តុះបណ្តាលបន្ទៃបន្ទុកសម្រាប់ជំនួយអ្នកមុខអ្នកចល័ត បើយើងមានទាហានជួរមុខមានទាហានជួរក្រោយ ។

ប៊ុនថនៈ ចឹងបើនៅខាងក្រោយអត់មាន?

សំអ៊ុនៈ អត់អ្នកខាងក្រោយគឺស្លាប់បាត់ហើយមានជំនួយមកពីណាទេ ។

ប៊ុនថនៈ ចឹងអត់មានជំនួយដោះស្រាយទេ?

សំអ៊ុនៈ អត់មានទេ វាឲ្យយើងបន្តបង្កើតផលឡើងផលឡាទាំងអស់ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ រួចហើយបន្ទៃបន្ទុកមិនថាស្អីៗទេ គឺជាអ្នកដឹងបញ្ជូនឲ្យគេទាំងអស់ បើអ្នកចល័តបែរទៅខាងណាគឺយើងបញ្ជូនទៅតាមនោះ ដូចកងដឹកជញ្ជូនចឹងបើនិយាយរួមទៅ ។

ប៊ុនថនៈ ចឹងនៅយូរទេនៅកងហ្នឹង?

សំអ៊ុនៈ ចាប់ពីពេលហ្នឹងមកតស៊ូយូរគ្រាន់ដែរ សឹកតែក្រពុលមុខនិយាយមិនកើតវែងឆ្ងាយណាស់ជីវប្រវត្តិខ្ញុំ សូម្បីគ្នាឯងមិនស្គាល់គ្នាឯងទៀតនោះ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ សូម្បីតែលោកគ្រូឯងធ្វើធំក៏មិនស្គាល់ខ្ញុំជាក្មួយដែរ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ អត់ធ្វើស្គាល់ទេ កាលនោះ គេបញ្ជាដាច់ណាត់ថាដឹកជញ្ជូនទៅឲ្យគេ កាលដែលខ្ញុំរស់នៅការលំបាកហ្នឹងចាប់ពី៧៨រហូតមកដល់៧៩លោកគ្រូគិតមើល ។

ប៊ុនថនៈ តែពូនៅក្នុងកងហ្នឹងរហូតកាលហ្នឹង?

សំអ៊ុនៈ បាទ!ខ្ញុំអត់មានទៅណាទេ លោកគ្រូខ្ញុំអត់មានទៅណាទេ ខ្ញុំជម្លៀសចេញពីភូមិហ្នឹងគឺខ្ញុំកលាងជីវិត ឆ្អឹងឪពុកមិនបានឃើញដល់សព្វថ្ងៃផង បន្តែបើខ្ញុំនៅសម័យនោះខ្ញុំក៏ជួយមិនបានដែរ ព្រោះសម័យនោះអត់មានពីណាជួយពីណាបានទេ ។

ប៊ុនថន: បាទ ។

សំអ៊ុន: ដោយសារថាខ្ញុំធ្វើការខុសដោយឡែកពីឪពុកខ្ញុំ ឪពុកខ្ញុំធ្វើការផ្សេងខ្ញុំធ្វើការផ្សេងដល់គេឪពុកខ្ញុំទៅសម្លាប់ផ្សេងទៅ ខ្ញុំមានហ៊ានរកទៅរកឪពុកខ្ញុំអីណាខ្ញុំជាប់ការងាររនេះ ។

ប៊ុនថន: បាទ ។

សំអ៊ុន: បើខ្ញុំរកទៅនោះខ្ញុំស្លាប់ដូចតែគ្នាហ្នឹង ។

ប៊ុនថន: គេចាប់គាត់ពីណាទៅលោកពូ?

សំអ៊ុន: ចាប់នៅក្នុងភូមិហ្នឹងឯងចាប់ប្រហែលជាម៉ោងបីរសៀល ។

ប៊ុនថន: បាទ ។

សំអ៊ុន: ពីម៉ោង៣រសៀលដល់ម៉ោង៩យប់ គេសម្លាប់មនុស្សមិនទាន់អស់មនុស្សរាប់រយក្បាលលោកគ្រូ ។

ប៊ុនថន: ស្លាប់នៅណាវិញ?

សំអ៊ុន: សម្លាប់នៅខាងត្បូងភូមិជើងវៀន ខាងជើងភូមិម៉ោមនុស្សបីរណ្តៅកូនក្មេងតូចតាមវាចាប់បោកឃើញតែសក់ឃើញតែឈាម វាគួរឲ្យផ្អែតណាស់លោកគ្រូ ។

ប៊ុនថន: កាលហ្នឹងពូនៅណាបានពូដឹង?

សំអ៊ុន: ខ្ញុំនៅចល័តហ្នឹងខ្ញុំចុះឈ្មោះចូលមហាជន បើខ្ញុំនៅជាមួយឪពុកម្តាយខ្ញុំ ខ្ញុំស្លាប់ទាំងអស់ ។

ប៊ុនថន: បាទ! ពូនៅភូមិណាវិញ?

សំអ៊ុន: ខ្ញុំនៅនេះឯង ។

ប៊ុនថន: ហើយពូដឹងតាមពីណាមកថាម្តាយឪពុកគេយកទៅសម្លាប់?

សំអ៊ុន: អត់មានដឹងមកពីណាទេ គឺដឹងខ្លួនឯងភ្នែកខ្លួនឯងស្គាល់ច្បាស់ខ្លួនឯងដឹងពីគំនិតខ្លួនឯង គេយកដឹកនៅមុខខ្ញុំ ខ្ញុំមិនបានទៅជួយឪពុកខ្ញុំរួចទេ ពីព្រោះខ្ញុំហ៊ានលូកដៃខ្ញុំស្លាប់ដូចគ្នា ខ្ញុំក៏មិនបានដឹងថាយកឪពុកម្តាយខ្ញុំទៅសម្លាប់ដែរ គេកុហក់ថាទៅរៀននយោបាយថាយកទៅរៀនសូត្រយកទៅឲ្យស៊ីអន្ករបាយរឹង ។

ប៊ុនថន: បាទ ។

សំអ៊ុន: គេកុហក់យើងនយោបាយខ្មែរក្រហមគឺស្អាតណាស់ ។

ប៊ុនថន: ចឹងពូឃើញផ្ទាល់ភ្នែក?

សំអ៊ុន: បាទ!ឃើញផ្ទាល់ភ្នែក ។

ប៊ុនថន: ចាប់យកទៅច្រើនទេ កាលចាប់យកទៅ?

សំអ៊ុនៈ	អូ! លោកគ្រូហើយនិយាយពីរទេះរាប់ក្បាលទាំងអស់មួយភូមិៗដឹកជញ្ជូនយកទៅទាំងអស់យកទៅសម្លាប់ស្រែកអិអុដូចជាខ្មោចឆៅខ្មោចឆ្នាមានអ្នកណាជួយអ្នកណាកើត ។

ប៊ុនថនៈ	អ្នកណានៅខាងណាជាអ្នកគ្រប់គ្រងហ្នឹង?

សំអ៊ុនៈ	សព្វថ្ងៃដែលគ្រប់គ្រង ។

ប៊ុនថនៈ	បាទ ។

សំអ៊ុនៈ	ប្រធានដែលគ្រប់គ្រងខ្ញុំស្រង់ឈ្មោះឲ្យច្បាស់លោកគ្រូ កាលនោះសហករណ៍គេផ្លាស់ប្តូរគ្នា ។

ប៊ុនថនៈ	បាទ ។

សំអ៊ុនៈ	កាលនោះលោក សា អែម សព្វថ្ងៃគាត់ឈរឈ្មោះគាត់នៅសហករណ៍យើងនេះស្អី តា អន លោកអន តែសព្វថ្ងៃគាត់ស្លាប់អស់ហើយ ។

ប៊ុនថនៈ	បាទ ។

សំអ៊ុនៈ	ស្លាប់អស់ហើយ វាស្លាប់ដោយជំងឺខ្លួនវា បើនិយាយរឿងហ្នឹងខ្ញុំឆ្អែត ។

ប៊ុនថនៈ	បាទ ។

សំអ៊ុនៈ	ចឹងរឿងចឹងខ្ញុំឆ្លើយតាំងពីយូរ វានឹកទៅគួរអណោចណាស់រឿងប្រវត្តិខ្មែរក្រហមនិយាយទៅលោកគ្រូបើនិយាយរឿងខ្មែរក្រហមសម័យ៧មករាចូលមកអាហ្នឹងខ្ញុំមកស្រាយមិននេះ ។

ប៊ុនថនៈ	បាទ! តែ៧មករាហ្នឹងពូទៅណាវិញ?

សំអ៊ុនៈ	ខ្ញុំនិយាយប្រាប់លោកគ្រូឯង៧មករាហ្នឹងខ្ញុំនឹកឃើញសម័យខ្មែរក្រហមដែលសម្លាប់ឪពុកម្តាយខ្ញុំមិនកម្មុយនីស្ត ។

ប៊ុនថនៈ	បាទ ។

សំអ៊ុនៈ	៧មករាយួនចូលមកមិនកម្មុយនីស្តដូចគ្នា ខ្ញុំនឹកឃើញថា៧មករាកម្មុយនីស្តដដែរ ។

ប៊ុនថនៈ	បាទ ។

សំអ៊ុនៈ	ដូចនេះខ្ញុំជិនះខ្លួនឯងដោយស្មគ្រដោយខ្លួនឯងទៅធ្វើចលនាតស៊ូមួយជាមួយក្រុមគណបក្សសឺន សាន ។

ប៊ុនថនៈ	បាទ ។

សំអ៊ុនៈ	ជាគណបក្សសេរីសុទ្ធសាធ ។

ប៊ុនថនៈ	បាទ ។

សំអ៊ុនៈ ដើម្បីតស៊ូប្រឆាំងជាមួយកម្មុយនីស្តរហូតដល់ត្រូវរូវគ្នាចរចារគ្នាត្រូវខ្ញុំក៏មកធ្វើការជាមួយរដ្ឋាភិបាលបានខ្ញុំពិការជើងនេះ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ បណ្តោញខ្មែរក្រហមប៉ៃលិនអីហ្នឹងគ្រប់កន្លែងទាំងអស់ ចឹងបានជាខ្ញុំពិការជើង ។

ប៊ុនថនៈ ចឹងកាលពូ៧៩ភ្លាមហ្នឹងពូទៅជាមួយតា សឺន សាន?

សំអ៊ុនៈ បាទ ។

ប៊ុនថនៈ ទៅនៅហ្នឹង?

សំអ៊ុនៈ ទៅនៅជាយដែនយើងជំរំសព្វថ្ងៃជំរំតស៊ូយើងជាយដែន ។

ប៊ុនថនៈ គេហៅជំរំអីវិញ?

សំអ៊ុនៈ គេហៅជំរំអំពិល ។

ប៊ុនថនៈ នៅជំរំអំពិល?

សំអ៊ុនៈ បាទ ។

ប៊ុនថនៈ ហ្នឹងនៅដីខ្មែរឬដីថៃ?

សំអ៊ុនៈ ដីខ្មែរលោកគ្រូកាលនោះ ។

ប៊ុនថនៈ បាទ!ជំរំអំពិល?

សំអ៊ុនៈ បាទ!ជំរំអំពិលកាលនោះ ហើយបង្កើតប្រជាជនប្រពន្ធទាហានរាប់រយរាប់ពាន់មិនធម្មតាទេ ។

ប៊ុនថនៈ ចឹងមានដែលប៉ះវៃគ្នាជាមួយទាហានវៀតណាមទេ កាលហ្នឹង?

សំអ៊ុនៈ កាលហ្នឹងរប់មិនអស់ទេ លោកគ្រូ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ព្រោះសង្គ្រាមយើងស្អប់កម្មុយនីស្តរឿងអីយើងមិនវៃជាមួយវៀតណាម វៀតណាមមិនមែនសេរីណា វៀតណាមកម្មុយនីស្ត ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ តា សឺន សានគាត់សេរី ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ នេះសួរទៅលោកគ្រូនេះជាប្អូនខ្ញុំនៅជំរំដូចគ្នា ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ មើលខ្ញុំនិយាយណាវៀតណាមបង្កើត៧មករាជាកម្មុយនីស្តទេ មិនមែនសេរីទេ មិនមែនរៀបចំសេរីទេ ជាកម្មុយនីស្តសុទ្ធ តា សឺន សានបានជាសេរី ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ សេរីពហុបក្ស សឺន សាន សម្តេចសីហនុជំនួយមកដើម្បីការពារគ្រប់គ្រងបងប្អូនមួយរយៈសិន ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ដើម្បីជៀសវាងកម្មុយនីស្តជិះជាន់ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ កុំឲ្យមានការមើលងាយរើតម្លៃដល់ប្រជាពលរដ្ឋបានបង្កើតសន្សឹមៗ ទៅបានប្រជាជនរាប់ម៉ឺនរាប់សែន ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ បានជាខ្ញុំតស៊ូតាំងពីនោះមករហូតចប់មកខ្ញុំមកនេះមក ។

ប៊ុនថនៈ ចឹងពូមានដែលចូលមកដល់នេះទេរឺអី ដែលចូលមកដល់ស្វាយចេកថ្មពួកអីទេ?

សំអ៊ុនៈ និយាយពីសមរភូមិវិញលោកគ្រូ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ខ្ញុំមិនចេះតែអួតទេ សម្តេចហ៊ុន សែនគាត់និយាយថាគាត់រាប់ទាំងពីគ្រាប់ផ្លោងមកមាន ១០៥ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ បើខ្ញុំរាប់តាំងពីការរើតប់និងបាញ់ទល់មុខគ្នាវាជាងពីររយសមរភូមិទៅទៀតបានជាខ្ញុំពិការចឹងតែខ្ញុំនិយាយធ្វើអីទៀតការងាររកទ្ធផុតទៅហើយ រឺមានប្រយោជន៍អីខ្មែរនិងខ្មែរ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ សង្គ្រាមខ្មែរនិងខ្មែរតើអ្នកនយោបាយហ្នឹង ។

ប៊ុនថនៈ ចឹងពូចូលមកដល់ហ្នឹងនិងទៅកន្លែងផ្សេងជាច្រើនកន្លែង?

សំអ៊ុនៈ បាទ! ប្រពន្ធខ្ញុំ ខ្ញុំចុះតាំងពីបញ្ជាថ្នាក់លើមកដើម្បីខ្ញុំចុះធ្វើការមកដើម្បីពង្រៀមកម្មុយនីស្តយួន ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ យួនកម្មុយនីស្តគេសរសេរថាកុំយកនេះអក្សរយមួយទៀយដើងយមួយទៀតកម្មុយនីស្ត ខ្ញុំចុះមកដល់កំពង់ធំ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ បឹងកាំឆាំជាមួយសមរភូមិកក់ក្តៅបំផុត ខ្ញុំវ៉ៃកម្មុយនីស្តយួនឃ្លានចេញដោយសារអីវ៉ាចង់បានប៉ារ៉ាវ៉ាថាឲ្យតែវ៉ៃប៉ារ៉ាបានគឺវ៉ាមានប៊ីចេងវ៉ាបានសាក់កាដូវ៉ាបានសម្ភារ តែចំពោះប៉ារ៉ាខាងសឺន សានទៅមានអីរលាយយួនអស់ប៉ុន្មានកងពល ប៉ុន្មានរយកងពលនោះខ្ញុំនិយាយថាអួតទៅចុះ ថតចុះកាសែតកាលហ្នឹង ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ខ្ញុំចុះដល់ទន្លេសាបដល់ទាំងអស់ជាមួយបងគឹម សុភ័ណ្ឌយើង ។

ប៊ុនថនៈ គឹមសុភ័ណ្ឌ?

សំអ៊ុនៈ បាទ!គឹម សុភ័ណ្ឌគាត់កសាងសាលាបានមួយបន្ទប់ហ្នឹង កាលនោះឯងគាត់រំដោះបានត្រង់គាត់ជួយត្រង់ហ្នឹងឥឡូវដឹងគាត់នៅណា ។

ប៊ុនថនៈ ចឹងគាត់នៅរស់ទេរាល់ថ្ងៃហ្នឹង?

សំអ៊ុនៈ មិនដឹងទេ មិនដឹងជាគាត់ទៅណាទេ គាត់រស់គាត់រស់ហើយមិនដឹងជាគាត់នៅណា ។

ប៊ុនថនៈ កាលហ្នឹងគាត់ប្រធានរបស់ពូ?

សំអ៊ុនៈ គាត់ជាប្រធានចលនាតស៊ូ ចេញពីអគ្គសេនាធិការយើងដែរ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ គាត់នៅក្រោមបង្គាប់របស់លោកតា សឺន សាន ។

ប៊ុនថនៈ ចឹងមានដៀង ដែល?

សំអ៊ុនៈ ដៀង ដែលគឺអគ្គសេនាធិការទូទៅម៉ាជាយដែនម៉ាប្រធានដំរីគឺឯកឧត្តមសឺន សានគាត់មិនបាននៅទេ គាត់នៅតែប្រទេសក្រៅទេ តែគាត់ដើរនយោបាយធ្វើម៉េចឲ្យតែកូនចៅមានសុវត្ថភាព ។

ប៊ុនថនៈ ចុះឥឡូវគាត់នៅណាដៀង ដែលហ្នឹង?

សំអ៊ុនៈ ដៀង ដែលហ្នឹងគាត់នៅភ្នំពេញ នៅភ្នំពេញគាត់នៅជាប់ជាមួយហ៊ុន សែន ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ចុះកាលខ្ញុំទៅវ៉ៃបៃលិននោះខ្ញុំជួបគាត់ដែលគាត់ជិះអាស្កុតជាមួយហ៊ុន សែន ។

ប៊ុនថនៈ ចុះពូជាមួយកំលាំងខ្មែរក្រហមវិញមានដែលប៉ះគ្នាទេ?

សំអ៊ុនៈ ខ្មែរក្រហមដូចខ្ញុំថាចឹងវាម្ដងម្កាលវាជាខ្មែរដូចគ្នាមែន ប៉ុន្តែវាមិនត្រង់និងពាក្យសម្ដីវាមិនត្រូវហ្នឹងគំនិតនយោបាយវាមិនត្រូវគោលការណ៍របស់ថ្នាក់លើវាជួនវាប្រឆាំងវាប្រឆាំងជាមួយខ្ញុំជួនវាល្អ វាល្អជាមួយខ្ញុំ តែវាប្រឆាំងមួយភាគតូច ។

ប៊ុនថនៈ ប្រឆាំងយ៉ាងម៉េចវិញ?

សំអ៊ុនៈ ប្រឆាំងត្រូវបាញ់គ្នាគឺបាញ់ តែវាខ្មែរដូចគ្នាតែនយោបាយវាខុសគ្នាពីយើងមួយសេរីមួយកម្មុយនីស្ត ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ពាក្យថាខ្មែរក្រហមកម្មុយនីស្តណា លោកគ្រូឯងគិតមើល ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ហើយកម្មុយនីស្តនិងសេរីវាខុសគ្នា ជួនកាលវាល្អយើងវាល្អណាស់ តែថ្ងៃណាមួយអាក្រក់បាញ់គ្នាព្រះ បាញ់គ្នាដូចរន្ទះ៨ទិសចឹងមិនមែនធម្មតាទេ ខ្មែរក្រហមណាស់ មិនមែនធ្វើសង្គ្រាមជាមួយវៀតណាមទេ ធ្វើសង្គ្រាមជាមួយខ្មែរក្រហមឆ្អិនជាងខ្ញុំធ្វើសង្គ្រាមជាមួយពួកកងពលទៀត ម៉ាជួរម៉ាឡៃប៉ៃលិន ធេមួយជា១០ទៀតនោះ តែពេលល្អ ល្អមួយភ្លេត ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ដូចសង្គ្រាមយើងព្រះវិហារាល់ថ្ងៃហ្នឹង តែល្អៗតែមុខទេ ក្រោយដាក់គ្នាភឹង ។

ប៊ុនថនៈ ចឹងមានដែលវៃដល់ម៉ាឡៃទេ?

សំអ៊ុនៈ អូស!ប៉ៃលិនវៃហួសម៉ាឡៃហ្នឹងទៀត រហូតដល់ចុចកាំភ្លើងអត់ឮសូរឭដល់កន្លែងតំបន់ខ្ញុំទៀតនោះ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ រឿងកាត់កំនិចមនុស្សស្មុគស្មាញតែមានប្រវត្តិ បើមិនមានប្រវត្តិខ្ញុំមិនសម្ភាសន៍ហើយនិយាយជាលោកគ្រូឯងកើតទេ ។

ប៊ុនថនៈ អាហ្នឹងទៅវៃជាមួយខ្មែរក្រហម?

សំអ៊ុនៈ អត់ទេ បាទៗៗវៃជាមួយខ្មែរក្រហម ព្រោះខ្ញុំកាលនោះច្របាច់បញ្ចូលគ្នាជាមួយរដ្ឋាភិបាល ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ បញ្ចូលជាមួយរដ្ឋាភិបាលពីបមួយកងពលខ្ញុំមានរថក្រោះ៨គ្រឿងវៃផ្ដាច់ ។

ប៊ុនថនៈ កងពលប៉ុន្មានពូ?

សំអ៊ុនៈ កងពលទី៧ ។

ប៊ុនថនៈ កងពលទី៧?

សំអ៊ុនៈ បាទ!រថក្រោះ៤គ្រឿងវៃផ្តាច់ប៉ិតចឹងឈរដើងឡើងបែកខ្ចិចខ្ចីរអស់រលីងឡើងបានជ័យជំនះបានសម្តេច...ដកមកនៅតាមបន្ទាយស្វាយចេកវិញ ។

ប៊ុនថនៈ នៅខាងស្វាយចេកនេះពីណាជាអ្នកគ្រប់គ្រងខាងពូ?

សំអ៊ុនៈ ខាងមេដឹកនាំ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ខាងមេដឹកនាំមានសួរ ចាន់ហេងនិងឯកឧត្តមយោ ចៀន ។

ប៊ុនថនៈ យោ ចៀន?

សំអ៊ុនៈ បាទ ។

ប៊ុនថនៈ គាត់នៅណា?

សំអ៊ុនៈ គាត់នៅសព្វថ្ងៃ គាត់នៅសព្វថ្ងៃគាត់នៅភូមិភាគ៥ហ្នឹងបាត់ដំបងហ្នឹង ។

ប៊ុនថនៈ ចឹងពូកូនទាហានរហូតកាលហ្នឹង?

សំអ៊ុនៈ អត់ទេ និយាយពីរឿងប្រវត្តិហ្នឹងគេលើកសួយដែលយើងអួតអាងក៏វាអត់កើតដែរ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ពីដើមមិញខ្ញុំចាប់ផ្តើមបំរើឆ្នាំ៧៩ថ្ងៃទី៧ ខែ៦ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ខ្ញុំ៧មកភាគេចូលភ្នំពេញហ្នឹងពេលវៀតណាមចូលដល់ហ្នឹង?

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ បានខ្ញុំចាក់ចេញពីភូមិកំណើតទៅធ្វើការជាមួយចលនាតស៊ូ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ បន្តបន្ទាប់បើនិយាយទៅបច្ចុប្បន្ន អួតខ្លួនក៏វាមិនកើតដែរ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ កាលនោះខ្ញុំចាប់ផ្តើមតស៊ូរយៈពេល៤ខែ ខ្ញុំគេដំឡើងជាមេក្រុមមិនមែនជាមេក្រុមធម្មតាទេ មេក្រុមឲ្យទៅរៀននៅស្រុកក្រៅនោះបើយើងហៅប្រធាន"ង" ប្រធាន"គ" យើងសព្វថ្ងៃណាស់ ។

ប៊ុនថន៖ បាទ ។

សំអ៊ុន៖ ខ្ញុំលំដាប់មេក្រុមគេឲ្យទៅរៀននៅ«បេដឺ» «បេដឺ»មានស៊ីញ៉ៅតា សឺន សាន ស៊ីញ៉ៅ ដៀល ដែលចេញមកពីថ្នាក់លើ ស៊ីញ៉ៅចេញមកពីអ្នកនយោបាយហ្នឹងស៊ីញ៉ៅមកបោះត្រាមានសញ្ញាបត្រត្រឹមត្រូវរៀនឡើងឋានៈបានជាបីខែខ្ញុំចូលការិយាល័យទី៣ ចូលការិយាល័យទី៣នៅគៀកសេនាធិការកងអនុសេនាធំនោះលោកគ្រូ ។

ប៊ុនថន៖ បាទ ។

សំអ៊ុន៖ ហើយដល់ពេលនោះទៅបានគេដកខ្ញុំពីនោះមកឲ្យខ្ញុំនៅកងការពារ ឲ្យរៀបចំការពារដើម្បីរៀបចំពួកអាសិតក្រចេះកាំភ្លើងធំ ។

ប៊ុនថន៖ បាទ ។

សំអ៊ុន៖ ពួកអាសិតក្រចេះកាំភ្លើងធំ ឲ្យរៀបចំកងកាំភ្លើងក្រុមរបស់ខ្ញុំមាន១២នាក់ ។

ប៊ុនថន៖ បាទ ។

សំអ៊ុន៖ ខ្ញុំរៀបចំកាន់កាំភ្លើងធំប្រហែលជាបីខែតទៅទៀតបានគេចាប់ផ្ដើមដកគេទៅនោះឲ្យខ្ញុំទៅកាន់ការិយាល័យទី៤ ព្រោះមានកងកាំភ្លើងធំវាមានរងខ្ញុំហើយណាស់ ។

ប៊ុនថន៖ បាទ ។

សំអ៊ុន៖ គេធ្វើការជំនួសខ្ញុំគេឲ្យនៅការិយាល័យទី៤ មិនមែននៅកងធំទេខ្ញុំឡើងទៅដល់វរៈសេនាតូច ។

ប៊ុនថន៖ បាទ ។

សំអ៊ុន៖ ឡើងដល់វរៈសេនាតូចការងាររបន្ទុកទាំងអស់គ្រប់យ៉ាងកងធំនៅក្រោមបញ្ជារបស់ខ្ញុំ ។

ប៊ុនថន៖ បាទ!វរៈសេនាតូចលេខប៉ុន្មានពូ?

សំអ៊ុន៖ វរៈសេនាតូច២០៧ ។

ប៊ុនថន៖ ២០៧?

សំអ៊ុន៖ បាទ!ចាំដល់សព្វថ្ងៃអត់មានភ្លេច ។

ប៊ុនថន៖ បាទ!ពូមានដូរទៅណាទៀតទេ?

សំអ៊ុន៖ អត់មានទេ ។

ប៊ុនថន៖ នៅ២០៧ហ្នឹង?

សំអ៊ុន៖ នៅ២០៧ហ្នឹង៧០៧ដឹងដល់ខេត្តទៀតនោះវរៈ២០៧នោះ ។

ប៊ុនថន៖ បាទ ។

សំអ៊ុនៈ វរៈ២០៩ខាងក្រោមបន្ទុបន្ទាប់ប៉ុន្តែនៅក្នុងតំបន់៦ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ វាមាន៣វរៈសេនាធំ តែខ្ញុំចាំតែវរៈខ្ញុំ ។

ប៊ុនថនៈ ចឹងនៅតាមព្រំដែនហ្នឹងមានខ្មែរក្រហមមានអីទេ?

សំអ៊ុនៈ ខ្មែរក្រហមអត់មានទេ លោកគ្រូខ្ញុំប្រឆាំងដាច់ខាតគឺអត់មានទេ កាលណាតំបន់ពួកខ្ញុំនៅគឺអត់មានទេ មានជួបគ្នានៅពេលធ្វើការតែប៉ុណ្ណោះឯង គេនៅតំបន់អន្លង់វែងពេលចុះមកជួបគ្នាគឺបាញ់គ្នា គឺអត់មាននិយាយភាសាខ្មែរស្តាប់គ្នាបានទេ កាលនោះ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ថ្វីត្បិតតែយើងត្រូវរូវគ្នាមែនខ្មែរនិងខ្មែរតស៊ូប្រឆាំងនិងវៀតណាមឈ្លានពានមែនប៉ុន្តែគេខ្មែរដូចគ្នាគេមិនស្តាប់យើងទេ យើងជាសេរីគេកុម្មុយនីស្ត ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ដល់យើងខ្មែរសេរីយើងអត់សុខចិត្តជាមួយគេដាក់គ្នាមួយប្រ៉ាវពីរប្រ៉ាវទៅមានរបួសមានស្លាប់ អង្រឹងគាត់ក៏មានដែលរត់ចោលពេញព្រៃ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ខ្មែរនិងខ្មែរតែមានឈ្មោះខ្មែរក្រហមយើងជាខ្មែរសេរី ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ វាខុសគ្នាត្រង់ហ្នឹង ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ចឹងបានសរុបលទ្ធផលទៅវាឃើញទេ លទ្ធផលវាហុចទៅណាដូចខ្ញុំនិយាយចឹង ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ខ្ញុំជាខ្មែរខ្ញុំជាប្រជាជនស្លូតត្រង់ដែលខ្មែរក្រហមសម្លាប់ឪពុកខ្ញុំមិនបានទៅជួយឪពុកខ្ញុំរួចទេ គេសម្លាប់ពេញណាពេញណី ខ្ញុំបានសំណាងហើយបានខ្ញុំរស់ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ មកពីខ្ញុំព្រាមចំបានជាខ្ញុំធ្វើមិនរួចកាលហ្នឹង ចលនាតស៊ូហ្នឹងខ្ញុំរត់ទៅរកសេរី ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ពីព្រោះឪពុកខ្ញុំធ្វើទាហាន ខ្ញុំធ្វើទាហានគេយកប្រវត្តិទាហានយកវៃចោល ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ គេយកប្រវត្តិទាហានយកទៅវៃចោលយកទោសម្ចាប់ចោលដល់ខ្ញុំរស់តែម៉ាខ្លួនក្បាលខ្ញុំ ខ្ញុំនឹកឃើញចេះឯងព្រុច ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ជាយដែនដិតតើព្រុចទៅដល់ចូលដីឯកឧត្តមសឺន សាន ជួបឯកឧត្តមអគ្គសេនាធិការ ដៀល ដែល ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ និយាយពីចាត់ការត្រឹមត្រូវសេរីគឺកាំភ្លើងខោអាវបើកដូចយើងសព្វថ្ងៃចឹង ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ អត់មានកុម្មុយនីស្តទេ ខោអាវប៉ាវាយើងធម្មតាច្បាប់មកក៏សេរីសរសេរយ៉ាងណាក៏សេរី ដែរ ។

ប៊ុនថនៈ តែពូមកដល់ភូមិនេះឆ្នាំណាវិញ?

សំអ៊ុនៈ ខ្ញុំមកដល់ឆ្នាំ៩២លោកគ្រូ ។

ប៊ុនថនៈ ៩២?

សំអ៊ុនៈ បាទៗ ។

ប៊ុនថនៈ ពូមកពីជំរំ?

សំអ៊ុនៈ បាទ!៩២ឆ្នាំ៩៨ខ្ញុំរបួសខ្ញុំប្រចាប់ចូលជាចលនាខេមរភូមិន្ទ ចូលជាមួយរដ្ឋាភិបាលយើង វៃជាមួយខ្មែរក្រហម ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ខ្ញុំចូលជាមួយរដ្ឋាភិបាលយើងវៃគ្រប់កន្លែងវៃនៅប៉ៃលិន ភ្នំវល្លិណាវៃទាំងអស់ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ រហូតដល់មេចរចារគ្នាត្រូវបានខ្ញុំចាប់ផ្តើមរបួសនៅពេលដែលខ្ញុំវៃឈរជើងហ្នឹងឯង ។

ប៊ុនថនៈ របួសនៅណាវិញ?

សំអ៊ុនៈ របួសនៅសមរភូមិភ្នំឆត្រ ភ្នំប្រាក់យើងនៅបឹងត្រកួនហ្នឹង ។

ប៊ុនថនៈ កាលហ្នឹងវៃជាមួយខ្មែរក្រហម?

សំអ៊ុនៈ វៃជាមួយខ្មែរក្រហមក្រាលមីនដូចកន្ទេល សុទ្ធតែក្រាលមីនសុទ្ធតែរបស់សូរវៀតទៀតវា ក្រាល វាដោះបានវាយកដាក់ការពារទីតាំងរបស់វាមិនមែនរបួសតែខ្ញុំទេ របួសដល់ស្លាប់ អស់មិនចេះតិចទេ ។

ប៊ុនថន:	បាទ ។

សំអ៊ុន:	យើងដណ្ដើមទីតាំងរបស់វាយើងចង់លុបបំបាត់កុម្មុយនីស្តកាលនោះយើងជាមួយរដ្ឋាភិបាលហើយហ្នឹង ។

ប៊ុនថន:	កាលហ្នឹងពីណាដឹកនាំពូ?

សំអ៊ុន:	កាលប្រធានកងពលយើងរដ្ឋាភិបាលយើងដឹកនាំកាលហ្នឹងហ៊ុន សែន ដឹកនាំមិនលាក់បាំងអីទេ ហ៊ុន សែន ស្រែកពីលើរថក្រោះខ្ញុំប្រាប់ ។

ប៊ុនថន:	បាទ ។

សំអ៊ុន:	បញ្ហាដាច់ណាច់ឲ្យខ្មែរក្រហមចេញអស់ពីទឹកដីខ្មែរ វាំមែនកាលហ្នឹងមេអ៊ី ឈាន តា ម៉ុកតាមាំងអីណាអីណៃ នៅប៉ៃលិនសព្វថ្ងៃនោះតា ស្អី មិនមែនប៉ុល ពតទេ ប៉ុល ពតដឹងថាងាប់បាត់ហើយនៅតាសព្វថ្ងៃទៀវ សំដននោះ ។

ប៊ុនថន:	បាទ ។

សំអ៊ុន:	ទើបចរចារគ្នាត្រូវទើបឈប់វ៉ៃគ្នា ។

ប៊ុនថន:	បាទ ។

សំអ៊ុន:	ដល់ឈប់វ៉ៃគ្នាទៅមានណាខ្មែរនិយាយទៅវាវែងឆ្ងាយណាស់ ។

ប៊ុនថន:	ចឹងពូត្រូវរបួសហ្នឹងពូត្រូវរបួសពេលវ៉ៃនៅភ្នំឆ័ត្រ?

សំអ៊ុន:	ពេលវ៉ៃនៅសមរភូមិខ្ញុំវ៉ៃខ្ញុំឈរជើងមួយអាទិត្យវ៉ៃបែកបន្ទាយវាហើយខ្ញុំឈរជើងមួយអាទិត្យមិនមែនតែរបួសខ្ញុំទេ របួស៩ទៅ៦នាក់ហើយស្លាប់៦នាក់ទៀត ។

ប៊ុនថន:	ដាន់មីនឬមួយយ៉ាងម៉េច?

សំអ៊ុន:	បាទ!ដាន់មីនរបស់វាដាន់មីននៅលើសមរភូមិ ។

ប៊ុនថន:	បាទ ។

សំអ៊ុន:	វិជ្ជាជីវរបស់ខ្ញុំមានទាំងអស់ហ្នឹងខ្ញុំដេកពេទ្យគ្រាន់តែត្រូវពីបទៅអូសយកដាក់នៅមន្ទីរហ្នឹងមានសញ្ញាបត្រអី កាលហ្នឹងគេធ្វើខ្ញុំមិនបានដឹងខ្លួនដង តែចង់និយាយសួរលោកពូឯងថាចង់សួរពីប្រវត្តិពីដើមខ្ញុំធ្វើនេះធ្វើនោះឲ្យខ្ញុំនិយាយច្រើនណាស់ ។

ប៊ុនថន:	បាទ ។

សំអ៊ុន:	ទីបំផុតខ្ញុំជិន្នសការកងធំ ។

ប៊ុនថន:	បាទ ។

សំអ៊ុនៈ ការកេងធំវាស្មើហ្នឹង«ងប្រុយ»ស្អីទេខ្ញុំស្ដាប់មិនសូវយល់ន័យទេ ខ្ញុំធ្វើការបានវរៈសេនាតូច គ្រប់គ្រងបានទាំងអស់ទាំងយប់ថ្ងៃបើប្រធានវរៈមកខ្ញុំទំនេរ ប៉ុន្តែសកម្មជាងគេគឺក្រដាសបញ្ជីរ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ តុល្យាភាពមានស្ងាប់មានរបួសប៉ុន្មានលើខ្ញុំ វៃសមរភូមិណាលើខ្ញុំ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ហើយកាំភ្លើងខ្លីមានគ្រប់គ្នាចាប់ពីវរៈសេនាតូចដល់ស្នងការសព្វថ្ងៃពីដើមមិញថាជាសេនាធិការ ចាប់ពីសេនាធិការការិយាល័យទី៤មានកាំភ្លើងខ្លីទាំងអស់ ។

ប៊ុនថនៈ ចឹងក្រោយពីរបួសហើយពូនៅជាកងទ័ពដដែលឬមួយឈប់ហើយ?

សំអ៊ុនៈ បាទ! នៅជាកងទ័ពដដែល ។

ប៊ុនថនៈ ចឹងរាល់ថ្ងៃនេះ?

សំអ៊ុនៈ រាល់ថ្ងៃនៅជាប់ឈ្មោះជាយោធនពិការ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ យើងរំសាយហើយលោកគ្រូ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ យើងរំសាយពីកងទ័ព ។

ប៊ុនថនៈ ចឹងពូមានគ្រួសារពេលណាពូ?

សំអ៊ុនៈ គ្រួសារខ្ញុំមានតាំងពីឆ្នាំ៧៩មក ។

ប៊ុនថនៈ ចឹងពេលរត់ទៅនៅជាមួយ?

សំអ៊ុនៈ បាទ! ពេលរត់ទៅជាមួយចលនាតស៊ូណាស់ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ នៅជាមួយឯកឧត្តមសឺន សានគឺខ្ញុំបានប្រពន្ធដោយកំសត់កំរកតែម្ដងនៅលើជាយដែននេះ ។

ប៊ុនថនៈ បាទ ។

សំអ៊ុនៈ ប្រពន្ធខ្ញុំមិនឆ្ងាយទេ នៅស្រុកភូមិជាមួយគ្នា ។

ប៊ុនថនៈ បាទ! ទៅជួបគ្នានៅហ្នឹង?

សំអ៊ុនៈ បាទ ។

ប៊ុនថន: ខ្ញុំដូចជាអត់មានអីទៀតទេ ពូមានអីដែលពូចង់ចាំចង់បន្ថែមដែរ?

សំអ៊ុន: ខ្ញុំចង់បញ្ជាក់លុះត្រាតែលោកក្មួយឯងឆ្ងល់ពីកន្លែងណាមួយខ្ញុំឆ្លើយជូនបាន បើលោកក្មួយឯងអស់ខ្ញុំក៏អត់មានអីទេ បើសួរពីប្រវត្តិតស៊ូដើមឬប្រវត្តិចុងក្រោយនិយាយពីបច្ចុប្បន្នឬអតីតកាលនិយាយតែប៉ុណ្ណឹងបាន។

ប៊ុនថន: បាទ!ចឹងខ្ញុំដូចជាសួរពួរួចហើយ ខ្ញុំអរគុណច្រើនពូ?

សំអ៊ុន: បាទ។

**ចប់**